GMAC

Garment Manufacturers Association in Cambodia

# សេចក្តីជូនដំណឹង
## ស្តីពីការមកដល់នៃវត្ថុធាតុដើមសម្រាប់បម្រើឲ្យវិស័យកាត់ដេរ និងវិធានការសម្របសម្រួលពិសេសរបស់រាជរដ្ឋាភិបាល

ក្រោមកិច្ចអន្តរាគមន៍ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ទៅកាន់ភាគីចិន វត្ថុធាតុដើមសម្រាប់បម្រើឲ្យវិស័យកាត់ដេរត្រូវបានដឹកមកដល់កំពង់ផែស្វយ័តក្រុងព្រះសីហនុជាបណ្តើរៗហើយ កាលពីវេលាម៉ោង ១១ និង២៥នាទី យប់ នាថ្ងៃចន្ទ ទី៩ ខែមីនា ឆ្នាំ២០២០ តាមរយៈនាវាដឹកជញ្ជូនឈ្មោះ SITC Fujian។ រហូតដល់ថ្ងៃអាទិត្យចុងសប្តាហ៍នេះ យើងរំពឹងថាមានកប៉ាល់ចំនួន១២គ្រឿងនឹងចូលចតនៅកំពង់ផែក្រុងព្រះសីហនុជាមួយនិងវត្ថុធាតុដើមបន្ថែមទៀត។

ភ្លាមៗនោះ ទូកុងតែន័រទាំងអស់ត្រូវបានស្ទូចយកចេញពីនាវាមកដាក់នៅលើទីលានកុងតែន័រ។ ទន្ទឹមនេះ វិធានបន្ថែមប្រព្រឹត្តិកម្មច្រកបៃតង (Green Lane) ដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានជួយសម្របសម្រួលនីតិវិធី និងបែបបទបញ្ចេញទំនិញភ្លាមៗពីកំពង់ផែ ហើយបានដឹកជញ្ជូនទៅកាន់រោងចក្រនៅតាមតំបន់ផ្សេងៗ រួមទាំងរាជធានីភ្នំពេញផងដែរ។

លើសពីនេះទៅទៀត រដ្ឋបាលរាជធានីភ្នំពេញ ក្រោមការដឹកនាំរបស់ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានអនុញ្ញាតជាពិសេសឲ្យរថយន្តកុងតែន័រទាំងនោះអាចធ្វើចរាចរណ៍ចូលក្នុងរាជធានីភ្នំពេញបានទាំងពេលយប់ និងពេលថ្ងៃ និងបានចាត់វិធានការអោយមានការសម្រួលចរាចរណ៍ក្នុងករណីចាំបាច់នានា ដើម្បីធ្វើការដឹកជញ្ជូនសម្ភារៈវត្ថុធាតុដើមទាំងនោះទៅកាន់រោងចក្រដែលមានមូលដ្ឋាននៅក្នុងរាជធានីភ្នំពេញអោយបានឆាប់រហ័យ។

ក្នុងករណីពិសេស រដ្ឋបាលរាជធានីភ្នំពេញ ក៏បានត្រៀមផ្តល់ការអមដំណើរដល់រថយន្តកុងតែន័រទាំងនោះដើម្បីបញ្ចៀសការកកស្ទះ ឬការឃាត់ទុកដោយនគរបាលចរាចរណ៍ដែលបានកំពុងសម្រួលសណ្តាប់ធ្នាប់ ដោយមិនបានដឹងបានថាទំនិញទាំងនោះជាសម្ភារៈវត្ថុធាតុដើមសម្រាប់សម្រាប់បម្រើឲ្យវិស័យកាត់ដេរ។

ឆ្លៀតឱកាសនេះ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សូមអំពាវនាវដល់រោងចក្រដែលជាសមាជិក ក៏ដូចជាក្រុមហ៊ុន ដឹកជញ្ជូនទាំងអស់អោយបានជ្រាបអំពីកិច្ចសម្របសម្រួលពិសេសនេះ។ ក្នុងករណីជួបបញ្ហាហាមឃាត់មិនអោយចូលក្នុងរាជធានីភ្នំពេញ សូមធ្វើការទំនាក់ទំនង និងរាយការណ៍ភ្លាមៗមក៖

- លោក ហុក ហួលីម ទូរស័ព្ទលេខ ០១២៩៧៥៩៩៣ (សាលារាជធានីភ្នំពេញ)
- លោក តោ ដារ៉ាវិទូ ទូរស័ព្ទលេខ ០១២៨០៨០៨៤ (សមាគមរោងចក្រកាត់ដេរនៅកម្ពុជា)

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលដែលបានដាក់ចេញនូវវិធានការទាន់ពេលវេលាដើម្បីជួយសម្រួល និងកាត់បន្ថយផលប៉ះពាល់ដោយបញ្ហាខ្វះខាតការផ្គត់ផ្គង់វត្ថុធាតុដើមនេះ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Por Sen Chey, Phnom Penh, Cambodia.
Tel: (855) 23-301 181 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org